ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ
សាលក្រមព្រហ្មទណ្ឌ
លេខ ៥១៨ "ទ"
ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២៣
-សំណុំរឿងព្រហ្មទណ្ឌលេខ: ៦៣៣៨
ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២០
-សំណុំរឿងស៊ើបសួរលេខ: ៥៤៨៤
ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០២០
-សំណុំរឿងជំនុំជម្រះលេខ: ១២៣២
-ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២១

នាមនាមប្រជារាស្ត្រខ្មែរ
សាលាដំបូងរាជធានីភ្នំពេញ

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២៣ វេលាម៉ោង៨ និង ៣០ នាទីព្រឹក ដោយមានសមាសភាព ៖

ចៅក្រមជំនុំជម្រះ

លោក [redacted] ជាចៅក្រមសាលាដំបូងរាជធានីភ្នំពេញ

តំណាងអយ្យការ

លោក [redacted] ជាព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ

ក្រឡាបញ្ជីសវនាការ

លោក [redacted] ជាក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ៦៣៣៨ ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២០ ដែលមានជនជាប់ចោទ ឈ្មោះ [redacted] **ទិសេស** ភេទប្រុស អាយុ៤៨ឆ្នាំ ជនជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរវិស្វកររសំណង់ មានទីលំនៅបច្ចុប្បន្ន ស្នាក់នៅផ្ទះ [redacted] រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] ជន (ស្លាប់) ម្តាយឈ្មោះ [redacted] ថុល (រស់) ប្រពន្ធឈ្មោះ [redacted] កែវលីនណា មានកូនចំនួន០១នាក់ ទោសពីមុន គ្មាន។ (ក្រៅឃុំ)

ជាប់ចោទពីបទ **ទំលោភលើទំនុកចិត្ត** ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៦ បទល្មើសដែលមានចែងតាមមាត្រា ៣៩១ និងឱ្យផ្តន្ទាទោសតាមមាត្រា ៣៩២ នៃក្រមច្បាប់ព្រហ្មទណ្ឌ។

ដោយមានលោកមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទរួមមាន៖

-លោកមេធាវី [redacted] មានការិយាល័យ **ក្រុមមេធាវី ប្រ្គេនដ៍ (GLG)** មានទីតាំងនៅអគារលេខ២២(LH AROMA ជាន់ទី១) ផ្លូវលេខ២៤២ កែងផ្លូវលេខ ១០៧ សង្កាត់បឹងព្រលឹត ខណ្ឌ៧មករា រាជធានីភ្នំពេញ។

-លោកមេធាវី [redacted] មានការិយាល័យនៅផ្ទះលេខ២០បេ ផ្លូវលេខ៥៩៦ សង្កាត់បឹងកក់២ ខណ្ឌទួលគោក រាជធានីភ្នំពេញ។

-លោកមេធាវី [redacted] មានទីតាំងនៅអគារលេខ២២ ផ្លូវលេខ២៤២ កែវ១០៧ សង្កាត់បឹងព្រលឹត ខណ្ឌ៧មករា រាជធានីភ្នំពេញ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **ចន្ធនំដួល** ភេទប្រុស កើតនៅថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ១៩៨០ ជនជាតិខ្មែរ ទីលំនៅបច្ចុប្បន្នស្នាក់នៅផ្ទះលេខ២៤៨ ភូមិសន្សំកុសល២ សង្កាត់បឹងទំពុន ខណ្ឌមានជ័យ រាជធានីភ្នំពេញ ។

ដោយមានលោកមេធាវី [redacted] មានការិយាល័យនៅផ្ទះលេខ ៩០៣B ផ្លូវ៩A សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ជាមេធាវីការពារក្តីនិងតំណាងឱ្យដើមបណ្តឹងរដ្ឋប្បវេណី។

អង្គហេតុនៃរឿងអាទិភាពដូចតទៅៈ

កាលពីថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៦ ជនជាប់ចោទឈ្មោះ [redacted] **វិសេស** បានលក់ដីមួយកន្លែងទំហំ ១១៧០២ ម៉ែត្រការ៉េ ស្ថិតនៅឃុំព្រែកកំពិស ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ដែលមានបណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ B_{XVII} ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០០៩ ដែលចេញដោយប្រធានមន្ទីរនគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្តកណ្តាល ទៅឲ្យឈ្មោះ [redacted] **ច័ន្ទវឌ្ឍល** តាមកិច្ចសន្យាទិញលក់ដី ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៦ ក្នុងតម្លៃ ១៥០,០០០ (ដប់ប្រាំម៉ឺន) ដុល្លារអាមេរិក ដែលនៅក្នុងកិច្ចសន្យាតម្រូវឲ្យបង់ប្រាក់ចំនួន០៣លើក ក្នុងមួយលើកចំនួន ៥០,០០០ (ប្រាំម៉ឺន) ដុល្លារអាមេរិក ប៉ុន្តែដល់ដំណាក់កាលនៃការបង់ប្រាក់លើកទី២ ឈ្មោះ [redacted] **ច័ន្ទវឌ្ឍល** បានប្រគល់ប្រាក់សរុបទៅឲ្យជនជាប់ចោទឈ្មោះ [redacted]**សេស** តែចំនួន៦០,០០០ (ប្រាំមួយម៉ឺន) ដុល្លារអាមេរិកតែប៉ុណ្ណោះ ហើយជនជាប់ចោទបានផ្ទេរកម្មសិទ្ធិទៅឲ្យឈ្មោះ [redacted] **ច័ន្ទវឌ្ឍល** រួចហើយតាមប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ $ឆ_{IX}$ ០០៦៥ ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៦ ចេញដោយប្រធានមន្ទីរនគរូបនីយកម្ម សំណង់ សុរិយោដីរាជធានីភ្នំពេញ។ ក្រោយមកដើមបណ្តឹងរដ្ឋប្បវេណីពុំបានអនុវត្តទៅតាមកាតព្វកិច្ចក្នុងកិច្ចសន្យាឲ្យបានត្រឹមត្រូវ ទើបជនជាប់ចោទឈ្មោះ [redacted]**វិសេស** ពុំព្រមប្រគល់ប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ $ឆ_{IX}$ ០០៦៥ ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៦ ទៅឲ្យឈ្មោះ [redacted] **ច័ន្ទវឌ្ឍល** ហើយឈ្មោះ [redacted]**ច័ន្ទវឌ្ឍល** ក៏បានឈ្មោះ [redacted] **វិសេស** ពីបទ **រំលោភលើទំនុកចិត្ត** តែម្តង។

-**បានឃើញ** របាយការណ៍លេខ១៣៥/២០ របក ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០២០ របស់ការិយាល័យព្រហ្មទណ្ឌកំរិតធ្ងន់។

-**បានឃើញ** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ **៥៥១៣ អ.ឃ.ខ** ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២០ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-**បានឃើញ** ដីកាសន្និដ្ឋានស្តាពរលេខ **៩៧២ អ.ឃ.ខ** ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២១ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

-**បានឃើញ** ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ **១៦០៥ "ក" ដ.ដ** ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ។

នាពេលសវនាការ

-**អំណានចម្លើយរបស់ជនជាប់ចោទឈ្មោះ ខៀវ វិសេស** បានឆ្លើយថា៖ កាលពីថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៦ ខ្លួនពិតជាបានចុះកិច្ចសន្យាលក់ទិញដីមួយកន្លែងទំហំ ១១៧០២ ម៉ែត្រការ៉េ ដែលមានទីតាំងស្ថិតនៅសង្កាត់ព្រែកកំពិស ខណ្ឌដង្កោ រាជធានីភ្នំពេញ ជាមួយឈ្មោះ [redacted]**ច័ន្ទវឌ្ឍល** ប្រាកដមែន ដោយខ្លួនបានទទួលប្រាក់កក់លើកទី១ ចំនួន ៥០,០០០ ដុល្លារអាមេរិក និងបានធ្វើការរត់ការកាត់ឈ្មោះផ្ទេរកម្មសិទ្ធិឲ្យទៅឈ្មោះ [redacted] **ច័ន្ទវឌ្ឍល** តាមរយៈប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ B_{XVII} ០២២៦ ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៦ ដែលចេញដោយប្រធានមន្ទីរវៀបចំដែនដី នគរូបនីយកម្ម និងសុរិយោដីរាជធានីភ្នំពេញ។ ក្រោយពីបានផ្ទេរសិទ្ធិរួច ខ្លួនក៏បានថតចម្លងនូវឯកសារផ្ទេរសិទ្ធិផ្ញើទៅឲ្យឈ្មោះ [redacted] **ច័ន្ទវឌ្ឍល** មើល ក្រោយពីទទួលដំណឹងរួច ឈ្មោះ [redacted]**ច័ន្ទវឌ្ឍល** ត្រូវបង់ប្រាក់ចំនួន ៥០,០០០ (ប្រាំម៉ឺន) ដុល្លារអាមេរិក ដូចនេះគាត់មិនបានធ្វើការទូទាត់ប្រាក់តាមកិច្ចសន្យាទិញលក់ទេ និងមិនបានបង់ប្រាក់បង្គ្រប់រហូតដល់សព្វថ្ងៃ។ បន្ទាប់មក ខ្លួនបានរត់ការប្តូរដីពី ដីប្រភេទ ផ.ក (កសិកម្ម) ទៅជាដីសាងសង់ថែមទៀត ដើម្បីឲ្យឈ្មោះ [redacted]**ច័ន្ទវឌ្ឍល** បំពេញកាតព្វកិច្ចតាមកិច្ចសន្យា និងបានព្យាយាមទំនាក់ទំនងជាមួយឈ្មោះនេះជាច្រើនដង តែគាត់មិនបានបង់ប្រាក់បង្គ្រប់តាមកិច្ចសន្យាមកឱ្យខ្លួនដដែល។

ទំព័រទី២

ក្នុងរឿងនេះដែរឈ្មោះ [redacted] **ច័ន្ទវិរ្ឈូល** បានប្តឹងខ្លួនទៅតុលាការរដ្ឋប្បវេណីទាមទារឱ្យខ្លួនប្រគល់ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុខាងលើទៅឱ្យគាត់ ទាំងដែលខ្លួនមិនបានគោរពតាមកិច្ចសន្យាទិញលក់ផង ហើយនៅពេលនេះតុលាការរដ្ឋប្បវេណីមិនទាន់បានសម្រេចនៅឡើយ។

-អំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **ច័ន្ទវិរ្ឈូល** បានឆ្លើយថា៖ ចំពោះការទិញលក់ដីពីឈ្មោះ [redacted] **វិសេស** នោះខ្លួនបានកក់ប្រាក់ចំនួន ៦០,០០០ (ប្រាំមួយម៉ឺន) ដុល្លារអាមេរិក ក្រោយពីទទួលព័ត៌មានពីឈ្មោះ [redacted] **វិសេស** ដែលគាត់រត់ការបានលិខិតផ្ទេរសិទ្ធិរួចគាត់បានថតចម្លងផ្ញើមកឱ្យខ្លួនពិនិត្យ ហើយខ្លួនបានចូលរៀបចំសែនដីក៏ត្រូវបានប្រជាជនជាច្រើនមកអះអាងថាជាដីរបស់ពួកគេ។ នៅពេលនោះខ្លួន និងឈ្មោះ [redacted] **វិសេស** បានធ្វើបណ្តឹងរួមគ្នាប្តឹងប្រជាជនទាំងនោះចូលមកអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ដូចមាននៅក្នុងសំណុំរឿងព្រហ្មទណ្ឌលេខ ២១៧៩ ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៦ តាមសាលក្រមលេខ ៣០២០ (ដ) ចុះថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០១៧ ហើយរហូតមកដល់ពេលនេះ ខ្លួនពុំទទួលបានលិខិតកាន់កាប់ និងចូលកាន់កាប់ដីនៅឡើយ ក្រោយមកខ្លួនក៏បានជូនដំណឹងទៅលើឈ្មោះ [redacted] **វិសេស** ដើម្បីគាត់មកទទួលប្រាក់ដែលនៅសល់ និងឱ្យគាត់ប្រគល់លិខិតកាន់កាប់មកឱ្យខ្លួន តែលិខិតនោះត្រូវបានសមត្ថកិច្ចប៉ុស្តិ៍បញ្ជាក់ថាឈ្មោះ [redacted] **វិសេស** មិនព្រមទទួល ។ នៅក្នុងរឿងនេះខ្លួនសុំឱ្យឈ្មោះ [redacted] **វិសេស** ប្រគល់លិខិតកាន់កាប់ដីមកខ្លួន ហើយខ្លួននឹងប្រគល់ប្រាក់គ្រប់ចំនួនទៅឱ្យគេដែរ។

•សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ៖

ក្រោយពីធ្វើការពិភាក្សាដេញដោលនាពេលសវនាការរួចមកឃើញថា **អង្គហេតុ**នៅក្នុងរឿងនេះកើតចេញកិច្ចសន្យាលក់ទិញដីមួយកន្លែងទំហំ ១១៧០២ ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅសង្កាត់ព្រែកកំពិស ខណ្ឌដង្កោ រាជធានីភ្នំពេញ រវាងឈ្មោះ [redacted] **ច័ន្ទវិរ្ឈូល** និងជនជាប់ចោទឈ្មោះ [redacted] **វិសេស** តំណាងអយ្យការយល់ឃើញថា **អង្គហេតុ**នេះជារឿងក្តីរដ្ឋប្បវេណីដូច្នេះតំណាងអយ្យការស្នើសុំឱ្យតុលាការសម្រេចតាមច្បាប់។

•សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ៖

លោកមេធាវី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋានថា៖ ទាក់ទងនឹងសំណុំរឿងនេះឃើញថា វាគឺជារឿងរដ្ឋប្បវេណីសុទ្ធសាធ ដែលកើតចេញពីការមិនអនុវត្តកាតព្វកិច្ចរបស់ដើមបណ្តឹងរដ្ឋប្បវេណី។ មួយវិញទៀតខាងដើមបណ្តឹងរដ្ឋប្បវេណីគាត់បានទទួលស្គាល់ថា គាត់ និងជនជាប់ចោទពិតជាអ្នកទិញ និងអ្នកលក់មែន ហើយខាងជនជាប់ចោទឈ្មោះ [redacted] **វិសេស** ក៏បានអនុវត្តកាតព្វកិច្ចរបស់គាត់រួចហើយ ដោយគាត់បានធ្វើការកាត់ឈ្មោះ និងប្តូរប្រភេទដីទៅឱ្យដើមបណ្តឹងរដ្ឋប្បវេណី ប៉ុន្តែខាងដើមបណ្តឹងរដ្ឋប្បវេណីពុំបានប្រគល់ប្រាក់ទៅតាមពេលកំណត់នៅក្នុងកិច្ចសន្យាឡើយ ដោយគាត់មិនបានប្រគល់ប្រាក់គ្រប់ចំនួនទៅឱ្យជនជាប់ចោទនោះទេ ហើយបែរជាគាត់ដាក់ពាក្យបណ្តឹងប្តឹងជនជាប់ចោទពាក់ព័ន្ធនឹងការរំលោភលើទំនុកចិត្តទៅវិញ។ ចំពោះ**អង្គហេតុ**ទាក់ទងនឹងសំណុំរឿងខាងលើនេះគឺពុំមានពាក់ព័ន្ធនឹងអំពើរំលោភលើទំនុកចិត្តនោះទេ មានតែខាងដើមបណ្តឹងមិនព្រមអនុវត្តនូវកាតព្វកិច្ចទៅតាមកិច្ចសន្យារបស់ខ្លួនតែប៉ុណ្ណោះ ហើយក្នុងរឿងរដ្ឋប្បវេណីតុលាការកំពូលក៏បានសំអាងថា ភាគីដើមបណ្តឹងជាអ្នកមានកំហុស ដោយគាត់មិនអនុវត្តកាតព្វកិច្ចរបស់ខ្លួន។ យោងតាមក្រមនីតិវិធីព្រហ្មទណ្ឌ និងរដ្ឋធម្មនុញ្ញ បានកំណត់ថា វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ។ ដូច្នេះខ្ញុំបាទស្នើសុំឱ្យតុលាការសម្រេចឱ្យកូនក្តីខ្ញុំបាទរួចខ្លួនពីបទចោទ។

-ក្រោយពីបានស្តាប់អំណានចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្តាប់អំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ

-ក្រោយពីបានពិនិត្យលើឯកសារ ភស្តុតាងនានាក្នុងសំណុំរឿង

-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

<u>សំអាងហេតុ</u>

១.តាមដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ: ១៦០៥ (ភ) ដ.ដ ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០២១ ចៅក្រមស៊ើបសួរបានសម្រេចបញ្ជូនជនជាប់ចោទឈ្មោះ [redacted] **វិសេស** ទៅជំនុំជម្រះ ពីបទ **រំលោភលើទំនុកចិត្ត** ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៦ បទល្មើសដែលមានចែងតាមមាត្រា៣៩១ និងឲ្យផ្តន្ទាទោសតាមមាត្រា ៣៩២ នៃក្រមព្រហ្មទណ្ឌ។

២.តាមអំណានចម្លើយរបស់ជនជាប់ចោទបានបញ្ជាក់ថា៖ កាលពីថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៦ ខ្លួនបានចុះកិច្ចសន្យាលក់ទិញដីមួយកន្លែងចំហំ ១១៧០២ ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅសង្កាត់ព្រែកកំពិស ខណ្ឌដង្កោ រាជធានីភ្នំពេញ ជាមួយឈ្មោះ [redacted] **ច័ន្ទវិរ្ឈូល** ខ្លួនបានទទួលប្រាក់កក់លើកទី១ចំនួន ៥០,០០០ ដុល្លារអាមេរិករួចបានធ្វើការរត់ការកាត់ឈ្មោះផ្ទេរកម្មសិទ្ធិឲ្យទៅឈ្មោះ [redacted] **ច័ន្ទវិរ្ឈូល** (ប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ ៥១០៤០ ឆIX ០០៦៥ ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៦ ដែលចេញដោយប្រធានមន្ទីរវៀបចំដែនដី នគរូបនីយកម្ម និងសុរិយោដីរាជធានីភ្នំពេញ)ហើយបានធ្វើការប្តូរដីពី ដីប្រភេទ ផ.ក (កសិកម្ម) ទៅជាដីសាងសង់ថែមទៀត។ ក្រោយពីបានផ្ទេរសិទ្ធិរួចខ្លួនបានថតចម្លងឯកសារផ្ទេរសិទ្ធិផ្ញើទៅឲ្យឈ្មោះ [redacted] **ច័ន្ទវិរ្ឈូល** មើល។ ប៉ុន្តែឈ្មោះ [redacted] **ច័ន្ទវិរ្ឈូល** មិនបានធ្វើការទូទាត់ប្រាក់តាមកិច្ចសន្យាទិញលក់រហូតដល់សព្វថ្ងៃហើយខ្លួនបានព្យាយាមទំនាក់ទំនងជាមួយឈ្មោះ [redacted] **ច័ន្ទវិរ្ឈូល** ជាច្រើនដង តែគាត់មិនបានបង់ប្រាក់បង្គ្រប់តាមកិច្ចសន្យាដដែល។ ចម្លើយនេះមានភាពស៊ីសង្វាក់គ្នាទៅនឹងភស្តុតាងដែលមានក្នុងសំណុំរឿងដែលអាចឲ្យតុលាការលើកយកមកធ្វើការពិចារណាបាន។

៣.តាមការអះអាងរបស់ជនជាប់ចោទបានបញ្ជាក់ថា៖ ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **ច័ន្ទវិរ្ឈូល** បានប្តឹងខ្លួនទៅតុលាការរដ្ឋប្បវេណីទាមទារឲ្យខ្លួនប្រគល់ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុខាងលើទៅឲ្យគាត់ ហើយនៅពេលនេះតុលាការរដ្ឋប្បវេណីកំពុងតែចាត់ការតាមនីតិវិធី។

៤.តាមអះអាងរបស់ដើមបណ្តឹងរដ្ឋប្បវេណីបានបញ្ជាក់ថា៖ ខ្លួនបានទិញលក់ដីពីឈ្មោះ [redacted] **វិសេស** ដោយបានកក់ប្រាក់ចំនួន ៦០,០០០ (ប្រាំមួយម៉ឺន)ដុល្លារអាមេរិក ហើយឈ្មោះ [redacted] **វិសេស** បានរត់ការផ្ទេរកម្មសិទ្ធិឱ្យខ្លួនរួចហើយ ប៉ុន្តែខ្លួនបានចូលរៀបចំសែនដីក៏ត្រូវបានប្រជាជនជាច្រើនមកអះអាងថាជាដីរបស់ពួកគេ នៅពេលនោះខ្លួននិងឈ្មោះ [redacted] **វិសេស** បានធ្វើបណ្តឹងរួមគ្នាប្តឹងប្រជាជនទាំងនោះចូលមកអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ *(សំណុំរឿងព្រហ្មទណ្ឌលេខ ២១៧៩ ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៦ តាមសាលក្រមលេខ ៣០២០ (ដ) ចុះថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០១៧)* ហើយរហូតមកដល់ពេលនេះ ខ្លួនពុំទទួលបានលិខិតកាន់កាប់ និងចូលកាន់កាប់ដីនៅឡើយ។ នៅក្នុងរឿងនេះខ្លួនសុំឲ្យឈ្មោះ [redacted] **វិសេស** ប្រគល់លិខិតកាន់កាប់ដីមកខ្លួន ហើយខ្លួនទឹងប្រគល់ប្រាក់គ្រប់ចំនួនទៅឲ្យគាត់។

៥.ផ្អែកតាមសាលក្រមរដ្ឋប្បវេណីលេខ ១៤៣ (ដ១) ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០២១ របស់សាលាដំបូងរាជធានីភ្នំពេញបានសម្រេចសេចក្តីឲ្យដើមចោទ(ឈ្មោះ [redacted] **ច័ន្ទវិរ្ឈូល** និងឈ្មោះ [redacted] **សេភា**)ធ្វើនីតិវិធីចុះបញ្ជីអំពីការលុបការចុះបញ្ជីផ្ទេរកម្មសិទ្ធិលើអចលនវត្ថុមានប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ ៥១០៤០ ឆIX00៦៥ ចុះថ្ងៃទី២៥ ខែមករា

ទំព័រទី៤

ឆ្នាំ២០១៦ ដែលចេញដោយប្រធានមន្ទីរវៀបចំដែនដី នគរូបនីយកម្ម និងសុរិយោដីរាជធានីភ្នំពេញ ដីនោះទៅឲ្យជនជាប់ចោទ ឈ្មោះ [redacted] **វិសេស** ជាថ្នូរនឹងការទទួលនូវការបង់ពីឈ្មោះ [redacted] **វិសេស** ចំនួន ៦០,០០០ (ប្រាំមួយម៉ឺន) ដុល្លារអាមេរិក។

៦.ផ្អែកតាមសាលដីកាលេខ ៥២ ក្រIII (ឃ) ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០២១ របស់សាលាឧទ្ធរណ៍រាជធានីភ្នំពេញបានសម្រេចសេចក្តីថា លុបចោលសាលក្រមរដ្ឋប្បវេណីលេខ ១៤៣ (ជ១) ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០២១ របស់សាលាដំបូងរាជធានីភ្នំពេញ ហើយក្រោយមកតុលាការកំពូលបានសម្រេចបង្វិលសំណុំរឿងទៅឲ្យសាលាឧទ្ធរណ៍ភ្នំពេញធ្វើការជំនុំជម្រះសារឡើងវិញ ដោយផ្អែកតាមសាលដីកាលេខ ៣៤២ (ខ) ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២១ របស់តុលាការកំពូល។

៧.តាមប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ ៤១០៤០ ធIX00៦៥ ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៦ ដែលចេញដោយប្រធានមន្ទីរវៀបចំដែនដី នគរូបនីយកម្ម និងសុរិយោដីរាជធានីភ្នំពេញឃើញថា ជនជាប់ចោទឈ្មោះ [redacted] **វិសេស** ពិតជាបានធ្វើការផ្ទេរកម្មសិទ្ធិអចលនវត្ថុខាងលើនោះទៅឲ្យឈ្មោះ [redacted] **ច័ន្ទរំដួល** រួចរាល់ហើយប្រាកដមែន។

៨.ផ្អែកតាមចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី, អំណានចម្លើយរបស់ជនជាប់ចោទ និងភស្តុតាងនានាដែលមានក្នុងសំណុំរឿងឃើញថា ជនជាប់ចោទឈ្មោះ [redacted] **វិសេស** បានលក់ដីមួយកន្លែងទំហំ ១១៧០២ ម៉ែត្រការ៉េ ស្ថិតនៅឃុំព្រែកកំពិស ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ទៅឲ្យឈ្មោះ [redacted] **ច័ន្ទរំដួល** ដោយបានធ្វើកិច្ចសន្យាទិញលក់ដី ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៦ ក្នុងតម្លៃ ១៥០,០០០ (ដប់ប្រាំម៉ឺន) ដុល្លារអាមេរិក តម្រូវឲ្យបង់ប្រាក់ចំនួន០៣លើក ក្នុងមួយលើកចំនួន ៥០,០០០ (ប្រាំម៉ឺន) ដុល្លារអាមេរិក ហើយឈ្មោះ [redacted] **ច័ន្ទរំដួល** បានប្រគល់ប្រាក់សរុបទៅឲ្យជនជាប់ចោទឈ្មោះ [redacted] **វិសេស** ចំនួន៦០,០០០(ប្រាំមួយម៉ឺន)ដុល្លារអាមេរិក ហើយឈ្មោះ [redacted] **វិសេស** បានផ្ទេរកម្មសិទ្ធិនិងប្តូរប្រភេទដីទៅឲ្យឈ្មោះ [redacted] **ច័ន្ទរំដួល** រួចហើយ ប៉ុន្តែដើមបណ្តឹងរដ្ឋប្បវេណីពុំបានអនុវត្តតាមកាតព្វកិច្ចតាមកិច្ចសន្យាទិញលក់ដី ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៦ឲ្យត្រឹមត្រូវ ទើបជនជាប់ចោទឈ្មោះ [redacted] **វិសេស** ពុំព្រមប្រគល់ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុទៅឲ្យដើមបណ្តឹងរដ្ឋប្បវេណីក៏ដើមបត្តឹងរដ្ឋប្បវេណីប្តឹងពីឈ្មោះ [redacted] **វិសេស** ពីបទ រំលោភលើទំនុកចិត្តតែម្តង។ តុលាការយល់ឃើញថា ពុំមានស្តុតាងដាក់បន្ទុកលើជនជាប់ចោទឈ្មោះ [redacted] **វិសេស** ពីបទ **រំលោភលើទំនុកចិត្ត** បទល្មើសដែលមានចែងតាមមាត្រា ៣៩១ និងឲ្យផ្តន្ទាទោសតាមមាត្រា ៣៩២ នោះឡើយ គឺជារឿងក្តីរដ្ឋប្បវេណីសុទ្ធសាធ។ ម៉្យាងទៀតដើមបណ្តឹងរដ្ឋប្បវេណីកំពុងតែប្តឹងឲ្យជនជាប់ចោទឈ្មោះ [redacted] **វិសេស** ប្រគល់ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុមកឲ្យខ្លួននៅតុលាការរដ្ឋប្បវេណី ហើយតុលាការកំពុងតែចាត់ការតាមនីតិវិធីផងដែរ។

៩.គ្មានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] **វិសេស** ភេទប្រុស អាយុ៤៨ឆ្នាំ មានអត្តសញ្ញាណខាងលើពីបទ **រំលោភលើទំនុកចិត្ត** ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៦ បទល្មើសដែលមានចែងតាមមាត្រា ៣៩១ និងឲ្យផ្តន្ទាទោសមាត្រា ៣៩២ នៃក្រមព្រហ្មទណ្ឌ ដូច្នេះតុលាការគប្បីសម្រេចឲ្យជនជាប់ចោទឈ្មោះ [redacted] **វិសេស** រួចខ្លួនពីបទចោទ ដោយយោងតាមមាត្រា ៣៥០ កថាខណ្ឌទី៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

១០.តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានប្តឹងស្នើសុំឲ្យតុលាការសម្រេចតាមច្បាប់នោះ មានសំអាងហេតុគ្រប់គ្រាន់អាចឲ្យតុលាការយកមកធ្វើការពិចារណាបាន។

១១.មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] **វិសេស** បានធ្វើសេចក្តីសន្និដ្ឋានស្នើសុំឲ្យតុលាការសម្រេចឲ្យកូនក្តីខ្លួនរួចខ្លួនពីបទចោទប្រកាន់នោះ មានហេតុផលគ្រប់គ្រាន់អាចឲ្យតុលាការលើកយកមកធ្វើការពិចារណាបាន។

<u>ហេតុដូច្នេះសម្រេច</u>

*ឲ្យជនជាប់ចោទឈ្មោះ [redacted] **វិសេស** ភេទប្រុស អាយុ៤៨ឆ្នាំ មានអត្តសញ្ញាណដូចខាងលើ ***រួចខ្លួនពីបទ***

វិសោតរលើចំនុកចិត្ត ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៦ បទល្មើសដែលមានចែងតាមមាត្រា ៣៩១ និងឱ្យផ្តន្ទាទោសមាត្រា ៣៩២ នៃក្រមព្រហ្មទណ្ឌ។

សាលក្រមនេះជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២៣ កំប៉ាំងមុខជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណី និងប្រកាសជាសាធារណៈ នៅថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២៣ ទុកសិទ្ធិឱ្យប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

ក្រឡាបញ្ជីសវនាការ

ហត្ថលេខា និងត្រា ៖ [redacted]

ចៅក្រមជំនុំជម្រះ

ហត្ថលេខា និងត្រា ៖ [redacted]

"បានចម្លងត្រឹមត្រូវតាមច្បាប់ដើម"

ថ្ងៃចន្ទ ០១កើត ខែផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២៣

ក្រឡាបញ្ជីសវនាការ

[redacted]

បានឃើញ

ចៅក្រមជំនុំជម្រះ

[redacted]

Scanned with CamScanner